00250164

C20/5/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| សំណុំរឿងក្តីលេខ | : | 002/19-09-2007-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ(១៦) |
| ដាក់ជូន | : | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទរបស់ឯកសារ | : | ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ |
| ភាគីដាក់ជូនសារណា | : | មេធាវីការពារក្តីរបស់អ្នកស្រី **អៀង ធីរិទ្ធ** |
| ភាសាដើម | : | ភាសាអង់គ្លេស និងភាសាខ្មែរ (បកប្រែ) |
| ប្រភេទនៃឯកសារ | : | សាធារណៈ |

---

# បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ ប្រឆាំងនឹង
# "ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន"
# ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨

---

<u>ដាក់ជូនដោយ</u>:
**មេធាវីការពារក្តី របស់ អៀង ធីរិទ្ធ:**
ផាត់ ពៅស៊ាង
Diana ELLIS, QC

<u>ជូនចំពោះ</u>:
**អង្គបុរេជំនុំជម្រះ:**
ប្រាក់ គឹមសាន, ប្រធាន
ហ៊្វូត វុទ្ធី
Rowan DOWNING
នីយ ថុល
Katinka LAHUIS
ប៉ែន ពេជ្រសាលី
**សហព្រះរាជអាជ្ញា:**
ជា លាង
Robert PETIT
**មេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី:**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត
គីម ម៉េងឃី
Martin JACQUIN

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 09 / 12 / 2008
ម៉ោង (Time/Heure): 14h30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# មាតិការ

I សេចក្តីផ្តើម ........ 3
II ច្បាប់ជាធរមាន ........ 4
២.១ ច្បាប់ជាធរមានក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ........ 4
២.២ ច្បាប់ជាធរមានចំពោះសិទ្ធិនៅស្ងៀមមិនឆ្លើយតប ........ 7
III ការសំអាងហេតុ និងអង្គច្បាប់ ........ 7
៣.១ សេចក្តីសម្រេចសំអាងហេតុមិនគ្រប់គ្រាន់ ........ 8
៣.១.១ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនមិនមានអំណះអំណាងគ្រប់គ្រាន់ : មិនបានផ្តល់ប្រភព ........ 8
៣.១.២ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនមានព័ត៌មានមិនពិត ........ 10
៣.១.៣ មិនមានសិទ្ធិពេញលេញក្នុងការពិនិត្យមើលសំណុំរឿងឡើយ ........ 10
៣.១.៤ សេចក្តីសន្និដ្ឋាន ........ 11
៣.២ ការអនុវត្តបទដ្ឋានមិនត្រឹមត្រូវ ........ 12
៣.២.១. បទដ្ឋានដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ ជំនួសឲ្យបទដ្ឋានដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ជាពិសេស ........ 12
៣.២.២ "វិសាលភាពនៃកិច្ចស៊ើបសួរ" ជំនួសឲ្យភស្តុតាងដែលបានរកឃើញ ........ 16
៣.២.៣ ពេលវេលាមិនត្រឹមត្រូវត្រូវបានយកមកអនុវត្ត ........ 17
៣.២.៤ សេចក្តីសន្និដ្ឋាន ........ 19
៣.៣ ការរំលោភសិទ្ធិនៅស្ងៀមមិនឆ្លើយតប ........ 19
៣.៤ មិនបានបញ្ជាក់ពី "ហានិភ័យជាក់លាក់" ........ 23
IV. សេចក្តីសន្និដ្ឋាន ........ 27
V. សំណើ ........ 28

# I សេចក្តីផ្តើម

១. នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ លោកស្រី អៀង ធីរិទ្ធ ("ជនត្រូវចោទ") ត្រូវបានចាប់ខ្លួននៅផ្ទះរបស់លោកស្រីក្នុងទីក្រុងភ្នំពេញ អនុលោមតាមដីកាបង្គាប់ឲ្យនាំខ្លួន[1] ដែលបានចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ក.ស.ច.ស បានចេញដីកាឃុំខ្លួនបណ្តោះអាសន្នដល់ជនត្រូវចោទ សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំឡើយ អនុលោមតាមវិធាន៦៣ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង")[2]។

២. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ ក.ស.ច.ស បានចេញសេចក្តីជូនដំណឹងមួយ[3] បញ្ជាក់ថារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ ដែលបានកំណត់នៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ នឹងផុតកំណត់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយថាខ្លួនបានពិចារណាបន្តដីកានោះតទៅទៀត។ មេធាវីរបស់ជនត្រូវចោទត្រូវបានគេអនុញ្ញាតឲ្យដាក់សេចក្តីកត់សំគាល់របស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ មេធាវីការពារក្តីបានដាក់ "ការជំទាស់ប្រឆាំងនឹងគោលបំណងរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន លោកស្រី អៀង ធីរិទ្ធ" ("ការជំទាស់")[4] ដោយស្នើមិនឲ្យបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្នឡើយ ដោយឲ្យស្ថិតក្រោមលក្ខខណ្ឌជាក់លាក់វិញ។

---

[1] ដីកាបង្គាប់ឲ្យនាំខ្លួន ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧ លេខឯកសារ C13។

[2] ដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ លេខឯកសារ C20។

[3] សេចក្តីជូនដំណឹង ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ លេខឯកសារ C20/2។ មេធាវីការពារក្តីត្រូវបានគេជូនដំណឹងអំពីឯកសារនេះនៅថ្ងៃបន្ទាប់ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨។

[4] ការជំទាស់របស់មេធាវីការពារក្តីប្រឆាំងនឹងគោលបំណងរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន លោកស្រី អៀង ធីរិទ្ធ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារលេខ C20/3។

៣. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ក.ស.ច.ស បានចេញ "ដីកាសម្រេចស្ដីអំពីការបន្តថិរៈវេលាឃុំខ្លួនបណ្ដោះអាសន្ន" ("ដីកាសម្រេចអំពីការបន្តឃុំខ្លួន")[5] ដោយបន្តការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទសម្រាប់រយៈពេលមួយទៀតមិនលើសពីមួយឆ្នាំ ដោយអនុលោមតាមវិធាន ៦៣(៦)(ក) នៃវិធានផ្ទៃក្នុង។

## II ច្បាប់ជាធរមាន

### ២.១ ច្បាប់ជាធរមានក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនបណ្ដោះអាសន្ន

៤. អនុលោមតាមវិធាន ៧៤(ច) និង វិធាន ៧៥ នៃវិធានផ្ទៃក្នុង មេធាវីរបស់ជនត្រូវចោទធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនបណ្ដោះអាសន្ន។ ការបន្តថិរៈវេលាឃុំខ្លួនបណ្ដោះអាសន្នរបស់ ក.ស.ច.ស គួរតែផ្អែកទៅលើបទប្បញ្ញត្តិនៃវិធាន ៦៣ នៃវិធាន ផ្ទៃក្នុង។ វិធាន ៦៣(៧) ចែងថា :

> "ដីកាសម្រេចរបស់ [សហចៅក្រមស៊ើបអង្កេត] ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវមានសំអាងហេតុ ចំពោះការពន្យារពេលនៃការបន្តឃុំខ្លួនបណ្ដោះអាសន្ន។ ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន អាចធ្វើបានតែក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្ដល់រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដើម្បីទុកពេលឲ្យប្ដឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ការពន្យារពេលមិនត្រូវឲ្យលើសពី២(ពីរ)ដងបានឡើយ។ ដីកាសម្រេចនេះបើកផ្លូវប្ដឹងឧទ្ធរណ៍"។

និងវិធាន ៦៣(៣) ចែងថា :

> "[សហចៅក្រមស៊ើបអង្កេត] អាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម:
>
> មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

---

[5] ដីកាសម្រេចស្ដីអំពីការបន្តថិរៈវេលាឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ C20/4 ដែលមេធាវីការពារក្ដីបានទទួលឯកសារនោះនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨។

[សហចៅក្រមស៊ើបអង្កេត] យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បីៈ

(១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនឲ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ"។

៥. ក្រៅពីវិធានផ្ទៃក្នុង សន្និសញ្ញាស្តីអំពីសិទ្ធិមនុស្សជាច្រើន ជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ក៏អាចយកមកធ្វើជាសម្អាងបានដែរ មាត្រា ៩(៣) នៃ ICCPR ចែងថា :

> "បុគ្គលណាដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឲ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម"។

៦. មាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស ("ECHR") ស្រដៀងគ្នាទៅនឹងអត្ថន័យនៃបទប្បញ្ញត្តិរបស់កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") និងចែងដូចខាងក្រោមនេះ ៖

> "បុគ្គលណាដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ស្របតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ១(គ) នៃមាត្រានេះ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែងដោយរង់ចាំការជំនុំជម្រះ។ ការឲ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ"។

៧. ការបកស្រាយមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ("តុលាការអឺរ៉ុប") អាចមានគោលការណ៍ណែនាំដ៏មានសារៈសំខាន់នៅក្នុងការបកស្រាយរបស់តុលាការនេះអំពីសិទ្ធិរបស់ជនត្រូវចោទ ស្ថិតនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានទទួលស្គាល់ដោយ ក.ស.ច.ស នៅក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនរបស់ខ្លួន។

៨. ក្រៅពីបទប្បញ្ញត្តិសិទ្ធិមនុស្សជាក់លាក់ស្តីអំពីការឃុំខ្លួន (មុនការជំនុំជម្រះក្តី) មេធាវីការពារក្តីលើកឡើងថា: បទប្បញ្ញត្តិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ជាទូទៅនៃ មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា៦ នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស អាចត្រូវអនុវត្តបានដើម្បីកំណត់អំពីបញ្ហានៅចំពោះមុខនេះ។ មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា :

"១. ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងដែលបង្កើតឡើងដោយច្បាប់ (...) ក្នុងការសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ចំពោះបទល្មើសព្រហ្មទណ្ឌ ឬសិទ្ធិ និងកាតព្វដោយអនុលោមតាមច្បាប់។

២. (...)

៣. ក្នុងការសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាពេញលេញ ដូចខាងក្រោម :

(ក) (...)។

(ខ) (...)។

(គ) ត្រូវទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលយូរឡើយ។

(...)"។

៩. មាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស មានអត្ថន័យ និងការអនុវត្តស្រដៀងគ្នាទៅនឹងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងមាត្រា ១៤(៣)(ខ) បានសង្កត់ធ្ងន់ថែមទៀតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលយូរឡើយ។

## ២.២ ច្បាប់ជាធរមានចំពោះសិទ្ធិនៅស្ងៀមមិនឆ្លើយតប

១០. វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងចែងថា :

"ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាព របស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្ដល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

១១. មាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចែងអំពីសិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានគោរពនៅក្នុងដំណើរការជំនុំជម្រះក្ដី។ សិទ្ធិនេះរួមទាំងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ក្រោមមាត្រា ១៤(៣)(ឆ) និងការសន្មតជាមុនថាគ្មានទោសនៅក្នុងមាត្រា ១៤(២) នៃ កតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

១២. មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងចំពោះការសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវកំណត់ស្របតាមច្បាប់។ មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង :

ក្នុងការសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាពេញលេញ ដូចខាងក្រោម :

(...)

(ឆ) មិនត្រូវបានបង្ខំឱ្យធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ឬសារភាពកំហុសឡើយ។

(...)"។

## III ការសំអាងហេតុ និងអង្គច្បាប់

១៣. វិធាន ៧៥ នៃវិធានផ្ទៃក្នុង ចែងថា "ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍"។ មេធាវីការពារក្តីធ្វើការសន្និដ្ឋានថា ក.ស.ច.ស បានធ្វើឲ្យមានកំហុសជាច្រើនអំពីអង្គហេតុ និងអង្គច្បាប់នៅក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន ដែលកំហុសទាំងនោះធ្វើឲ្យមានបណ្តឹងឧទ្ធរណ៍នេះ។

## ៣.១ សេចក្តីសម្រេចសំអាងហេតុមិនគ្រប់គ្រាន់

១៤. សេចក្តីសម្រេចតាមផ្លូវតុលាការនីមួយៗ ត្រូវតែមានអំណះអំណាងក្នុងការធ្វើសេចក្តីសន្និដ្ឋាន។ នេះអាចត្រូវបានគេចាត់ទុកថាជាគោលការណ៍ច្បាប់ជាទូទៅ ដែលត្រូវបានទទួលស្គាល់ដោយតុលាការអឺរ៉ុប ដែលបានជំនុំជម្រះក្តីក្នុងករណី Hadjianastassiou ទល់នឹង Greece :

> "តុលាការជាតិត្រូវ (...) បង្ហាញអំពីហេតុផលច្បាស់លាស់គ្រប់គ្រាន់ដែលជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន។ ដែលក្នុងចំណោមមូលដ្ឋាននោះ វាអាចអនុញ្ញាតឲ្យជនជាប់ចោទអនុវត្តសិទ្ធិដ៏មានសារៈសំខាន់ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍"[6]។

១៥. លក្ខខណ្ឌនេះអនុវត្តស្រដៀងគ្នាទៅនឹងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន របស់ ក.ស.ច.ស ដែលតម្រូវឲ្យផ្តល់នូវអំណះអំណាងគ្រប់គ្រាន់សម្រាប់សេចក្តីសម្រេចរបស់ខ្លួន។ មេធាវីការពារក្តីសូមលើកឡើងថា ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន ដែលមានមូលហេតុជាច្រើន មិនបានបំពេញលក្ខខណ្ឌទាំងនោះទេ។

### ៣.១.១ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនមិនមានអំណះអំណាងគ្រប់គ្រាន់ : មិនបានផ្តល់ប្រភព

១៦. មេធាវីការពារក្តីសូមលើកឡើងថា ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន មិនមានអំណះ

---

[6] Hadjianastassiou ទល់នឹង Greece សាលក្រម តុលាការអឺរ៉ុប បណ្តឹងឧទ្ធរណ៍លេខ 12945/87 ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ កថាខណ្ឌទី៣៣។

អំណាងគ្រប់គ្រាន់ ដោយធ្វើការចោទប្រកាន់ជាទូទៅ ដោយមិនបានផ្តល់ប្រភពត្រឹមត្រូវទេ។ លើសពីនេះទៀត ជាពិសេស ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនបានចោទប្រកាន់ចំណុចជាច្រើន ដែលក្នុងនោះរួមមានៈ

- ក.ស.ច.ស បានប្រមូល "វត្ថុតាងបន្ថែមទៀត (...) វត្ថុតាងខ្លះផ្តល់ព័ត៌មាន ជាក់លាក់" ស្តីអំពីជនត្រូវចោទ[7]
- ជនត្រូវចោទមានសិទ្ធិពិនិត្យមើល "ភស្តុតាងមួយចំនួនធំ រួមមានសេចក្តីលំអិតស្តីអំពីតួនាទីរបស់ខ្លួនក្នុងរបបនោះ"[8]
- ក.ស.ច.ស បានប្រមូល "ភស្តុតាងមួយចំនួនធំ (...) ភស្តុតាងខ្លះផ្តល់ព័ត៌មានជាក់លាក់ស្តីអំពីតួនាទីជាសក្តានុពលរបស់ជនត្រូវចោទនៅក្នុងរបបនោះ"[9] និង
- មកដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ កំណត់ហេតុនៃការស្តាប់យកចម្លើយសាក្សីចំនួនជាង១០០ កំណត់ហេតុ ត្រូវបានដាក់នៅក្នុងសំណុំរឿង កំណត់ហេតុខ្លះបានផ្តល់ភស្តុតាងស្តីអំពីតួនាទីរបស់លោកស្រី អៀង ធីរិទ្ធ"[10]។

១៧. ក.ស.ច.ស មិនបានគូសបញ្ជាក់ឱ្យបានច្បាស់ថា ក្នុងរយៈពេលមួយឆ្នាំដែលជនត្រូវចោទស្ថិតនៅក្នុងការឃុំខ្លួនមុនការជំនុំជម្រះក្តី ក.ស.ច.ស បានប្រមូលភស្តុតាងសម្រាប់ដាក់បន្ទុកដោយផ្ទាល់ប្រឆាំងនឹងលោកស្រីឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ក.ស.ច.ស គ្រាន់តែយោងទៅលើភស្តុតាងដែលបង្ហាញពីសញ្ញាណមិនច្បាស់លាស់នៃ "តួនាទីដែលប្រហែលជាលោកស្រីធ្លាប់កាន់កាប់នៅក្នុងរបបនោះ"តែប៉ុណ្ណោះ។ ក.ស.ច.ស មិនបានផ្តល់នូវសេចក្តីយោងចំពោះថាតើ "ភស្តុតាងមួយចំនួនធំដែលមានសេចក្តីលំអិតអំពីតួនាទីដែលអាចមានរបស់លោកស្រីក្នុងរបបនោះ" ជាអ្វី ឬថាតើវាមានអ្វីខ្លះជាពិសេសនោះទេ។ ដូច្នេះ ក.ស.ច.ស ហាក់បីដូចជាគ្រាន់តែយោងទៅលើតួនាទីរបស់ជនត្រូវចោទ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដែលជាក់ស្តែងវាមិនមែនជា ឧក្រិដ្ឋកម្មស្ថិតនៅក្រោមច្បាប់អន្តរជាតិ និងមានមូលដ្ឋានមិនគ្រប់គ្រាន់សម្រាប់ការបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ននោះទេ។

---

[7] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី១៧។ សូមអាន ផ្នែក១៩ ខាងក្រោម ដែលពិភាក្សាអំពីប្រភពមិនត្រឹមត្រូវដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌនេះ។

[8] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី២៦។

[9] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី៣៨។

[10] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី៣៨។

៣.១.២ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនមានព័ត៌មានមិនពិត

១៨. បន្ថែមទៅអ្វីដែលបានបញ្ជាក់ខាងលើ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនមានព័ត៌មានមិនពិត ដែលជាថ្មីម្តងទៀតរំលោភទាំងវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង និងគោលការណ៍ច្បាប់ទូទៅ ដែលសេចក្តីសម្រេចតាមផ្លូវតុលាការតម្រូវឲ្យមានសំអាងហេតុ។

១៩. ក្នុងការគាំទ្រការចោទប្រកាន់របស់ខ្លួនដែលថា "មានព័ត៌មានជាក់លាក់ស្តីអំពីតួនាទីដែលជនត្រូវចោទអាចកាន់នៅក្នុងរបបនោះ"[11] ក.ស.ច.ស យោងនៅជើងទំព័រ ១៤ ក្នុងឯកសារពីរនៅក្នុងសំណុំរឿង ពោលគឺឯកសារ D88 និង D85/1 ដែលគ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំងពីរនោះមានបញ្ជាក់ពីឈ្មោះរបស់លោកស្រី អៀង ធីរិទ្ធ ឡើយ។

២០. មេធាវីការពារក្តីបានលើកឡើងថា ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន មានព័ត៌មានមិនពិត នៅក្នុងផ្នែកដ៏សំខាន់នេះនៃសេចក្តីសម្រេចរបស់ខ្លួន ហេតុដូច្នេះសេចក្តីសម្រេចនេះខ្វះនូវការគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា ភស្តុតាងត្រូវបានប្រមូលដើម្បីដាក់បន្ទុកដល់ការចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។

៣.១.៣ មិនមានសិទ្ធិពេញលេញក្នុងការពិនិត្យមើលសំណុំរឿងឡើយ

២.១ នៅក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនរបស់ខ្លួន ក.ស.ច.ស បានអះអាងថា "ជនត្រូវចោទមានសិទ្ធិពិនិត្យមើលសំណុំរឿងទាំងមូល រួមមាន កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[12]។

២២. នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ មុនពេលដែល ក.ស.ច.ស ចេញដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន មេធាវីការពារក្តីបានដាក់ "សំណើរបស់មេធាវីការពារក្តីសុំឲ្យមានការបញ្ជាក់ឲ្យបានច្បាស់អំពីវិធានជាធរមានស្តីអំពីការទទួលបានឯកសារសំណុំរឿងរបស់ជន

[11] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី១៧។

[12] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួន កថាខណ្ឌទី២៦។

ត្រូវចោទ" ជូនដល់ ក.ស.ច.ស[13] ដែលក្នុងនោះស្នើឱ្យមានការបញ្ជាក់ឱ្យបានច្បាស់អំពីវិធានដែលផ្ទុយគ្នា និងការអនុវត្តដែលនាពេលបច្ចុប្បន្ននេះបានកំហិតនូវសិទ្ធិរបស់ជនជាប់ឃុំឃាំងក្នុងការពិនិត្យមើលសំណុំរឿង។

២៣. ក.ស.ច.ស មិនទាន់បានឆ្លើយតបទៅនឹងសំណើនោះនៅឡើយទេ ដែលការមិនឆ្លើយតបនេះធ្វើឱ្យមានភាពមិនច្បាស់លាស់ ថាតើសិទ្ធិក្នុងការពិនិត្យមើលសំណុំរឿងទាំងមូលនឹងអាចធ្វើបានយ៉ាងដូចម្ដេចទៅ ពីព្រោះវាហាក់បីដូចជាពុំមានកន្លែងទំនេរនៅក្នុងមន្ទីរឃុំឃាំងដើម្បីអនុញ្ញាតឱ្យមានការពិនិត្យមើលសំណុំរឿងឱ្យបានពេញលេញឡើយ។ ដោយការខកខានមិនបានសម្រេចលើបញ្ហានេះរបស់ ក.ស.ច.ស មេធាវីការពារក្ដីនឹងផ្ដល់ឱ្យកូនក្ដីរបស់ខ្លួននូវឯកសារជាក់លាក់មួយចំនួននៃសំណុំរឿង ប៉ុន្តែពុំមានសិទ្ធិពេញលេញ ក្នុងការពិនិត្យមើលសំណុំរឿងដូចដែល ក.ស.ច.ស បានសន្មតនោះទេ។

២៤. នៅក្នុងសេចក្ដីគូសបញ្ជាក់ថា ជនត្រូវចោទមានសិទ្ធិពិនិត្យមើលសំណុំរឿងទាំងមូលបានដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន គឺមិនឆ្លុះបង្ហាញពីស្ថានភាពបច្ចុប្បន្នឡើយ ហើយវាមានលក្ខណៈមិនត្រឹមត្រូវទេ។ វារំលោភទៅលើលក្ខខណ្ឌដែលថា សេចក្ដីសម្រេចតាមផ្លូវតុលាការតម្រូវឱ្យមានសំអាងហេតុដោយអនុលោមតាមគោលការណ៍ច្បាប់ទូទៅនិងវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង។

### ៣.១.៤ សេចក្ដីសន្និដ្ឋាន

២៥. ដោយហេតុថា ក.ស.ច.ស (i)មិនបានផ្ដល់អំណះអំណាងគ្រប់គ្រាន់ចំពោះការអះអាងរបស់ខ្លួន (ii)បានផ្ដល់នូវព័ត៌មានមិនពិតទាក់ទិនទៅនឹងភស្តុតាងដែលត្រូវបានលើកឡើងប្រឆាំងនឹងជនត្រូវចោទ និង(iii)បានផ្ដល់នូវព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានមិនពិតស្ដីអំពីសិទ្ធិពិនិត្យមើលសំណុំរឿងរបស់ជនត្រូវចោទ ដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួនខ្វះខាត នូវអំណះអំណាង ដែលរំលោភទៅលើវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង និងគោលការណ៍ច្បាប់ទូទៅដែលបានបញ្ជាក់ពីខាងលើ។ កង្វះខាតបែបនេះគួរតែនាំឱ្យមានការទុកជាមោឃៈនូវដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួននេះ។

---

[13] សំណើរបស់មេធាវីការពារក្ដីសុំឱ្យមានការបញ្ជាក់ឱ្យច្បាស់នៃវិធានជាធរមានស្ដីអំពីការទទួលឯកសារសំណុំរឿងរបស់ជនត្រូវចោទ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារលេខ A228។

## ៣.២ ការអនុវត្តបទដ្ឋានមិនត្រឹមត្រូវ

### ៣.២.១. បទដ្ឋានដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ ជំនួសឱ្យ បទដ្ឋានដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ជាពិសេស

២៦. នៅក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ការិយាល័យសហចៅក្រមស៊ើបអង្កេតបានយកបទដ្ឋាន "នីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ"មកអនុវត្តក្នុងកិច្ចស៊ើបសួរដើម្បីកំណត់ថាកិច្ចស៊ើបសួរ ពិតជាបានគោរពទៅតាមនីតិវិធីក្នុងពេលវេលាមួយសមស្រប។ ក្នុងដីកានេះបានសម្រេចថា:

> "ក.ស.ច.ស ទទួលស្គាល់ថាពេលវេលាដែលកន្លងផុតទៅ គឺជាកត្តាមួយសម្រាប់យកមកធ្វើការពិចារណាដើម្បីសម្រេចពីលក្ខណៈសមស្រប នៃការរក្សាការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ។ ពេលវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលកន្លងផុតទៅនឹងមិនត្រូវបានចាត់ទុកថាមិនត្រឹមត្រូវទេ ប្រសិនបើមានភស្តុតាងបង្ហាញថាមាននីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"[14]។

២៧. នៅក្នុងសំណុំរឿង Tomasi v. France តុលាការអឺរ៉ុបបានថែងយ៉ាងច្បាស់ថា

> "អត្ថិភាព និងភាពស្ថិតស្ថេរនៃការបង្ហាញអំពីពិរុទ្ធភាព នៃបុគ្គលដែលពាក់ព័ន្ធបង្ហាញនូវកត្តាទាក់ទងមួយចំនួន ដោយគ្មានការសង្ស័យ ប៉ុន្តែទាំងតុលាការ និងគណៈកម្មាការបានពិចារណាឃើញថា កត្តាទាំងអស់នោះមិនទាន់បានធ្វើយុត្តិកម្មគ្រប់គ្រាន់សម្រាប់ការឃុំខ្លួនមុនការជំនុំជម្រះក្តី រយៈពេលយូរដូច្នោះទេ"[15]។

២៨. ក្នុងការកំណត់បទដ្ឋានមួយទៅលើពាក្យថាពេលវេលាសមស្រប ទាក់ទិននឹងការឃុំខ្លួនជាបណ្តោះអាសន្ន តុលាការអឺរ៉ុប សម្អាងតាមគណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស

---

[14] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី៣៥

[15] Tomasi v. France, សាលក្រម តុលាការអឺរ៉ុប លេខ១២៨៥០/៨៧ ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩២ កថាខណ្ឌទី៨៩

ដែលកាលនោះ បានកំណត់កាតព្វកិច្ចទៅលើអាជ្ញាធរតុលាការដូចតទៅ៖ តុលាការអឺរ៉ុបបាននិយាយយោងដល់ការពាក់ព័ន្ធគ្នា នៃរបៀបធ្វើការស៊ើបសួររួមមាន (i) ប្រព័ន្ធស៊ើបសួរជាធរមាន និង(ii)ការដឹកនាំការស៊ើបអង្កេតរបស់អាជ្ញាធរតុលាការជាក់ស្តែងដូចជា "ការយកចិត្តទុកដាក់របស់ពួកគេក្នុងការធ្វើការងារជាមួយសំណុំរឿង និងរបៀបនៃការរៀបចំការស៊ើបសួររបស់ពួកគេ" [16]។

២៩. ក្នុងសំណុំរឿង Stogmuller v.Austria តុលាការអឺរ៉ុបបានតាក់តែង ការទាមទារចាំបាច់ឲ្យមាន "នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ពិសេស" ដែលតម្រូវឲ្យអាជ្ញាធរតុលាការអនុវត្តពេលជនត្រូវចោទ ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន (ដែលមាត្រា៥(៣) ECHR នៅជាធរមាន)។ តុលាការអឺរ៉ុបបានសម្រេចថា:

> "មាត្រា ៥(៣) (មាត្រា ៥-៣) មាត្រានេះសំដៅតែទៅលើជនជាប់ចោទ និងជនជាប់ឃុំឃាំងប៉ុណ្ណោះ។ វាមានន័យថា ដាច់ខាតត្រូវមាននីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ពិសេស ក្នុងការចោទប្រកាន់ទៅលើរឿងក្តីណាមួយដែលមានជាប់ទាក់ទងនឹងពួកគេ"[17]។

៣០. អាស្រ័យហេតុនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបង្ហាញថាមាន "នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់" ដើម្បីធ្វើយុត្តិកម្មដល់ការឃុំខ្លួនបណ្តោះអាសន្ន ដែលនឹងត្រូវធ្វើបន្តទៅលើជនត្រូវចោទ។ នៅពេលនិយាយដល់"នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់" ក.ស.ច.ស បញ្ជាក់ថា វាមានលក្ខណៈស្រដៀងគ្នានឹងករណីយុត្តិសាស្ត្រនៃតុលាការអឺរ៉ុប[18]។ បើទោះជាយ៉ាងដូច្នេះក្តី ក្រុមមេធាវីការពារក្តីចង់បញ្ជាក់ដូចដែលមានបរិយាយនៅក្នុងសំណើជំទាស់ថា[19], តុលាការអឺរ៉ុបមិនត្រឹមតែ

---

[16] Wemhoff v. Germany សាលក្រម តុលាការអឺរ៉ុប លេខ ២១២២/៦៤ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨ កថាខណ្ឌទី២

[17] Stogmuller v. Austria សាលក្រម តុលាការអឺរ៉ុប លេខ១៦០២/៦២ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៩ កថាខណ្ឌទី៥ លក្ខខណ្ឌទាមទារនេះបានបញ្ចូលម្តងទៀត ទៅក្នុងករណីយុត្តិសាស្ត្រ ECHR ក្នុងឱកាសជាច្រើន សូមមើល Matznetter v. Austria សាលក្រម តុលាការអឺរ៉ុប លេខ២១៧៨/៦៤ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៩ កថាខណ្ឌទី១២ Calleja v. Malta, សាលក្រម តុលាការអឺរ៉ុប លេខ៧៥២៧៤/០១ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៥ កថាខណ្ឌទី១០០។

[18] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី៣៥

[19] ការជំទាស់តវ៉ា, កថាខណ្ឌ ៣៥

និយាយយោងទៅដល់ "នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់" ប៉ុណ្ណោះទេ ថែមទាំងនិយាយយ៉ាងច្បាស់ទៅដល់ "នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ជាពិសេស"ទៀតផង។ ពាក្យនេះមានដែនកំណត់ធំជាងពាក្យថា "នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ" ដែល ក.ស.ច.ស បានលើកឡើង[20]។

៣១. ដោយហេតុថាដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មិនបានអះអាងថា ខ្លួនប្រើពាក្យផ្សេងពីតុលាការអឺរ៉ុប ឬមិនបានផ្តល់ការពន្យល់អំពីភាពខុសគ្នារវាងពាក្យថានីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"ត្រឹមត្រូវ" និងពាក្យថានីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"ពិសេស"ក៏ដោយ ក៏មេធាវីការពារក្តីសូមសន្និដ្ឋានថា ក.ស.ច.ស មិនបានបង្ហាញឲ្យឃើញថាមាន នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"ត្រឹមត្រូវ"ឬនីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"ពិសេស"[21] នៅក្នុងកិច្ចស៊ើបសួរទៅលើជនត្រូវចោទ ចាប់តាំងពីមានការចាប់ខ្លួនអ្នកស្រីអៀង ធីរិទ្ធិ និងជាពិសេស ចាប់តាំងពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន[22]។

៣២. ក្នុងករណីណាក៏ដោយ ក.ស.ច.ស មិនបានឆ្លើយតបទឡ្ហីករណ៍របស់មេធាវីការពារក្តីថា ក.ស.ច.ស គួរតែអនុវត្តនីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់"ពិសេស"។ ទង្វើនេះរំលោភកាតព្វកិច្ចរបស់ក.ស.ច.ស ក្នុងការផ្តល់ហេតុផលទៅលើសេចក្តីសម្រេចរបស់ខ្លួន ដូចដែលបានតម្រូវដោយវិធាន ៦៣(៧)។

---

[20] សូមមើល Letellier v. France សាលក្រម តុលាការអឺរ៉ុប លេខ១២៣៦៩/៨៦ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩១ កថាខណ្ឌទី៣៥ និង Assenov v. Bulgaria សាលក្រម តុលាការអឺរ៉ុប លេខ២៤៧៦០/៩៤ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ កថាខណ្ឌទី១៥៧-១៥៨ (ឯកសារសម្អាងផ្លូវច្បាប់ទាំងពីរ មានភ្ជាប់មកជាមួយបណ្តឹងជំទាស់)

[21] វាជាទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលថាទាំងនីតិវិធីដែលប្រព្រឹត្តទៅដោយការយកចិត្តទុកដាក់ត្រឹមត្រូវ និងនីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ពិសេស មិនត្រូវបានគោរពតាម។ មេធាវីការពារក្តីនឹងនិយាយដល់បទដ្ឋានទាំងពីរនេះថាជា នីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់គ្រប់គ្រាន់ ពីត្រឹមនេះតទៅ ដើម្បីរាប់បញ្ចូលនិយមន័យទាំងពីរ។

[22] សេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់អៀង ធីរិទ្ធិ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨, ឯកសារលេខ C២០/១/២៦។

៣៣. ដោយហេតុថាជនត្រូវចោទត្រូវបានឃុំខ្លួនអស់ចំនួនជាងមួយឆ្នាំ ហើយក្នុងរយៈពេលនេះ ក.ស.ច.ស ខកខានមិនបានប្រមូលភស្តុតាងដាក់បន្ទុកលើជនត្រូវចោទ ដើម្បីគាំទ្រការចោទប្រកាន់មកលើជនត្រូវចោទ ដែលមានរៀបរាប់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរទេ បានន័យថា ក.ស.ច..ស ខកខានមិនបានបង្ហាញ ថាមាននីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ជាពិសេសក្នុងកិច្ចស៊ើបសួរទៅលើជនត្រូវចោទទេ។

៣៤. ការពិចារណារបស់គណៈកម្មាធិការសិទ្ធិមនុស្សក្នុង បទអត្ថាធិប្បាយទូទៅលេខ៨ (General Comment No.8) បញ្ជាក់ ថា"ការឃុំខ្លួនបណ្ដោះអាសន្ន គួរតែជាករណីលើកលែង និងមានរយៈពេលខ្លីផុតតាមការអាចធ្វើទៅបាន។ គណៈកម្មាធិការនឹងស្វាគមន៍ព័ត៌មានទាំងឡាយណា ដែលទាក់ទិននឹងយន្តការដែលមានស្រាប់ និងការចាត់វិធានការណ៍ ដើម្បីកាត់បន្ថយថេរៈវេលានៃការឃុំខ្លួន"[23]។ ជាពិសេសបើពិចារណាអំពីគោលការណ៍ខាងលើដែលមានចែងក្នុងច្បាប់អន្តរជាតិ យើងអាចសន្និដ្ឋានបានថា ក.ស.ច.ស ខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុវត្តនីតិវិធី ដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់នោះ ឲ្យបានគ្រប់គ្រាន់ទេ និងការឃុំខ្លួនជនជាប់ចោទរងចាំការកាត់ទោសឲ្យមានរយៈពេលខ្លីតាមដែលអាចធ្វើទៅបាន។

៣៥. សំអាងហេតុនេះបង្ហាញថា ក.ស.ច.ស ខកខានមិនបានបង្ហាញនីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់ ក្នុងការស៊ើបអង្កេតលើជនជាប់ចោទ។ នីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់នោះ គឺជានីតិវិធីដែល ក.ស.ច.ស ត្រូវអនុវត្តជាដាច់ខាតដើម្បីឲ្យ ក.ស.ច. ស. ច អាចបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៃជនត្រូវចោទ។ ដោយយល់ឃើញថា មានការខកខានមិនបានអនុវត្តនីតិវិធីខាងលើ ដូច្នេះដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ គួរត្រូវបានទុកជាមោឃៈ។

---

[23] គណៈកម្មាធិការសិទ្ធិមនុស្ស General Comment 8 មាត្រា៩ (សម័យប្រជុំលើកទី១៦ ឆ្នាំ១៩៨២) ការចងក្រងនៃ General Comments និង General Recommendations អនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ឯកសារ HRI/GEN/1/Rev.1 (១៩៩៤) កថាខណ្ឌទី៣ (តារាងឯកសារសម្អាងផ្លូវច្បាប់ មានភ្ជាប់មកជាមួយបណ្ដឹងជំទាស់នេះ)

៣.២.២ "វិសាលភាពនៃកិច្ចស៊ើបសួរ" ជំនួសឲ្យភស្តុតាងដែលបានរកឃើញ

៣៦. ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន បានបញ្ជាក់ថារយៈពេលមួយឆ្នាំដែលជនត្រូវចោទបានជាប់ឃុំបណ្តោះអាសន្ន មិនត្រូវបានគេគិតថាយូរនោះទេ "បើគិតអំពីវិសាលភាពនៃកិច្ចស៊ើបសួរនោះ"[24]។ បើទោះបីជាដូច្នេះក្តី មេធាវីការពារក្តីសូមអះអាងថាត្រង់ចំណុចនេះ ក.ស.ច.ស យកបទដ្ឋានខុសមកអនុវត្តជាថ្មី។ បទដ្ឋាននេះមិនមែនត្រឹមតែជាវិសាលភាពនៃកិច្ចស៊ើបសួរប៉ុណ្ណោះទេ ប៉ុន្តែថាតើ ក.ស.ច.ស អាចបង្ហាញថា ខ្លួនបានធ្វើអ្វីខ្លះ ដើម្បីស្វែងរកភស្តុតាងគាំទ្រការចោទប្រកាន់ជនត្រូវចោទក្នុងរយៈកាលមួយឆ្នាំកន្លងមកនេះ ក្នុងអំឡុងពេលដែលជនត្រូវចោទកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន។ ទោះជាអាចនៅមានការតវ៉ាក៏ដោយ កិច្ចស៊ើបសួរដែលគ្របដណ្តប់លើអង្គហេតុស្មុគស្មាញមួយចំនួនក៏ត្រូវធ្វើដែរ ប៉ុន្តែ ក.ស.ច.ស ក្នុងរយៈពេលមួយឆ្នាំនេះ មិនអាចមានលទ្ធភាពបង្ហាញភស្តុតាងដាក់បន្ទុកណាមួយ ទៅលើជនត្រូវចោទក្រៅតែពីជាការអះអាងថាជនត្រូវចោទជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនោះទេ ដូច្នេះបានសេចក្តីថាភាពស្មុគស្មាញ ឬវិសាលភាពនៃកិច្ចស៊ើបសួរ គឺមិនជាប់ពាក់ព័ន្ធអ្វីនឹងបញ្ហានេះទេ ឬមិនមានបទដ្ឋានគ្រប់គ្រាន់នោះ។ ការដែលថាក.ស.ច.ស គ្មានលទ្ធភាពបង្ហាញភស្តុតាងដាក់បន្ទុកជនត្រូវចោទ ក្នុងរយៈពេលមួយឆ្នាំដែលជនត្រូវចោទជាប់ឃុំ គឺអាចមកពី គ្មានភស្តុតាងតែម្តង ឬថា ក.ស.ច.ស មិនបានបង្ហាញថា ខ្លួនបានអនុវត្តនីតិវិធី ដែលប្រព្រឹត្តទៅដោយមានការយក ចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ ក្នុងកិច្ចស៊ើបសួររបស់ខ្លួន ហេតុដូច្នេះហើយ ក.ស.ច.ស មិនអាចមានលទ្ធភាពបង្ហាញភស្តុតាងដាក់បន្ទុកជនត្រូវចោទបានទេ។ នេះជាទង្វើមិនគួរកើត ហើយនាំមកនូវស្ថានភាពមួយដែលបណ្តាលឲ្យខូចប្រយោជន៍ជនត្រូវចោទ។

៣៧. វិសាលភាពនៃកិច្ចស៊ើបសួរ បូករួមនឹងភាពស្មុគស្មាញ និងទម្ងន់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ មិនមែនអនុញ្ញាតឲ្យមានការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ជាស្វ័យប្រវត្តិឡើយ។ ក.ស.ច.ស ចាំបាច់ត្រូវបង្ហាញថា ខ្លួនបាននឹងកំពុងបន្តធ្វើរាល់កិច្ចការក្នុងអំណាចខ្លួនក្នុងការអនុវត្ត និងបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹងជនត្រូវចោទ ដើម្បីឲ្យសំ

[24] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី៣៦។

ណុំរឿងនេះអាចទៅដល់ការជំនុំជម្រះក្តីឆាប់តាមការអាចធ្វើទៅបាន ឬដើម្បីឲ្យការចោទប្រកាន់ទៅលើជនត្រូវចោទត្រូវបានលើកលែង។

៣៨. ការពិតគឺថាខណៈពេលដែលជនត្រូវចោទ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ កាលពីឆ្នាំទៅម៉ិញនោះ ក.ស.ច.ស បានផ្តោតតែកិច្ចការរបស់ខ្លួនស្ទើរទាំងស្រុងទៅលើតែសំណុំរឿងលេខ០០១។ ប្រការនេះផ្ទុយនឹងការទាមទារដែលថា "ជនត្រូវចោទជាប់ឃុំមានសិទ្ធិ ឲ្យគេផ្តល់អទិភាពដល់សំណុំរឿងរបស់ខ្លួន ហើយដោះស្រាយក្នុងចិរៈវេលាជាក់លាក់មួយ" ដូចដែលបានតាក់តែងដោយតុលាការអឺរ៉ុប[25]។ យើងឃើញថាអាទិភាពនេះមិនត្រូវបានគេបង្ហាញឲ្យជនត្រូវចោទឃើញទេ។

៣៩. ការពិតគឺថា ក.ស.ច.ស ដែលកំពុងយោងទៅលើ "ដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើន" ដែល "កំពុងតែត្រូវបានអនុវត្ត"នោះ គឺមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ ក.ស.ច.ស ខកខានមិនបានបង្ហាញថាមាននីតិវិធីដែលប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងកិច្ចស៊ើបសួរទៅលើជនត្រូវចោទក្នុងរយៈកាលឆ្នាំកន្លងមក។ ជាលទ្ធផល ការតម្រូវឲ្យមានពេលវេលាមួយសមស្របត្រូវបានរំលោភ ហើយការឃុំខ្លួនបណ្តោះអាសន្នមិនអាចត្រូវធ្វើបន្តបាននោះទេ។

៣.២.៣ ពេលវេលាមិនត្រឹមត្រូវត្រូវបានយកមកអនុវត្ត

៤០. ដីកាសម្រេចបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នបញ្ជាក់ថា ក.ស.ច.ស "បានប្រមែប្រមូលភស្តុតាងបន្ថែម ចាប់តាំងពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ដែលភស្តុតាងមួយចំនួនបានផ្តល់ព័ត៌មានជាក់លាក់ទាក់ទិននឹងតួនាទី ដែលជនត្រូវចោទបានកាន់កាប់ ក្នុងរបបខ្មែរក្រហម"[26]។ មេធាវីការពារក្តីសូមអះអាងថា ផ្ទុយទៅនឹងអ្វីដែលដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នបានលើកឡើង ក.ស.ច.ស បានបរាជ័យក្នុងការស្វែងរកភស្តុតាងទាំងនោះ។

[25] Dzelili v. Germany សាលក្រម តុលាការអឺរ៉ុប លេខ ៦៥៧៤៥/០១ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌទី៧៧។

[26] ដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី១៧។

៤១. ក.ស.ច.ស បានអនុវត្តបទដ្ឋានមិនត្រឹមត្រូវ ក្នុងការកំណត់ថាតើខ្លួនមានភស្តុតាង (គ្រប់គ្រាន់) ដាក់បន្ទុកជនត្រូវចោទ ដើម្បីធ្វើឲ្យការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៤២. នៅក្នុងដីកាបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក.ស.ច.ស បានបញ្ជាក់ថា "បានប្រមែប្រមូលភស្តុតាងបន្ថែមចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ "[27]។ ក.ស.ច.ស អះអាងថាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានប្រើប្រាស់ ពីព្រោះនៅថ្ងៃនោះ អង្គបុរេជំនុំជម្រះបានបើកសវនាការស្តីពីបណ្តឹងឧទ្ធរណ៍ របស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន[28]។ មេធាវីការពារក្តីសូមអះអាងថា ការយកកាលបរិច្ឆេទនេះមកប្រើ គឺមិនសមហេតុផល ហើយថ្ងៃដែលចាប់ផ្តើមប្រមូលភស្តុតាងគួរតែជាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឲ្យយ៉ាងដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួនជនត្រូវចោទដែរ។ តុលាការអឺរ៉ុបចាត់ទុកថាកាលបរិច្ឆេទ ដែលជនត្រូវចោទត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំងថាជាចំណុចចាប់ផ្តើមនៃលក្ខខណ្ឌទាមទារអំពីពេលវេលាសមស្រប[29]។

៤៣. តាមរយៈការប្រើប្រាស់ពេលវេលាមួយមានកម្រិត ក.ស.ច.ស ហាក់ដូចជាអះអាងថា ខ្លួនបានខិតខំបំពេញកិច្ចការ និងប្រមូលបានភស្តុតាងច្រើន។ ទោះជាដូច្នេះក្តី ប្រសិនបើរយៈពេលមួយឆ្នាំពេញដែលជនត្រូវចោទស្ថិតក្នុងឃុំ ត្រូវបានគេយកមកធ្វើការពិចារណា ការខកខានមិនបានបង្ហាញភស្តុតាងណាមួយដាក់បន្ទុកផ្ទាល់ទៅជនត្រូវចោទ គួរតែត្រូវសន្និដ្ឋានថា ការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺមិនត្រូវបានអនុញ្ញាតនោះឡើយ។ ក.ស.ច.ស បានអនុវត្តនិយាមមិនត្រឹមត្រូវទេ។ ដូច្នេះជាលទ្ធផលដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នគួរចាត់ទុកជាមោឃៈ។

[27] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី១៧។ ត្រង់កថាខណ្ឌទី៣៨ ប្រើពាក្យពេចន៍ស្រដៀងគ្នា។

[28] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី១៥។

[29] សូមមើល Lettellier v. France សាលក្រម តុលាការអឺរ៉ុប លេខ១២៣៦៩/៨៦ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩១ កថាខណ្ឌទី៣៥។

៣.២.៤ សេចក្តីសន្និដ្ឋាន

៤៤. ដូចដែលបានបង្ហាញខាងលើ ក.ស.ច.ស បានអនុវត្តបទដ្ឋានខុសចំនួនបីផងផ្សេងៗគ្នា ដែលបានឈានទៅដល់ការធ្វើសន្និដ្ឋានមិនត្រឹមត្រូវ និងមិនមានលក្ខណៈគ្រប់គ្រាន់ដែលបានបង្កើតជាមូលដ្ឋាននៃដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ ហេតុដូច្នេះ ការសន្និដ្ឋាននៃដីកាសម្រេចបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គ្មានមូលដ្ឋានសំអាងហេតុ ឬច្បាប់ទេ ហើយដីកានេះគួរទុកជាមោឃៈ។

## ៣.៣ ការរំលោភសិទ្ធិនៅស្ងៀមមិនឆ្លើយតប

៤៥. ក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលាឃុំខ្លួន ក.ស.ច.ស បានបញ្ជាក់ដូចខាងក្រោមៈ

> "សហចៅក្រមស៊ើបអង្កេតរម្លឹកថា សិទ្ធិមិនឆ្លើយតបត្រូវបានទទួលស្គាល់ និងមិនអាចត្រូវគេជំទាស់។ សិទ្ធិរបស់មេធាវីជនត្រូវចោទ មិនព្រមសហការជាមួយអាជ្ញាធរតុលាការ អំឡុងពេលមានកិច្ចស៊ើបសួរ ក៏មិនអាចត្រូវបានគេជំទាស់ដែរ។ ទោះជាដូច្នេះក្តី ឥរិយាបទនេះពុំបាននាំឲ្យមានកិច្ចដំណើរការនីតិវិធីឲ្យទាន់ពេលសមស្របឡើយ"[30]។

៤៦. ដូច្នេះ ក.ស.ច.ស ចង់បញ្ជាក់ថាកិច្ចស៊ើបសួរ ពុំបានបោះជំហានលឿន ដូចពួកគេចង់បាននោះទេ។ ទង្វើនេះប៉ះពាល់ដល់ការទាមទារឲ្យមានពេលវេលាសមស្រប ហើយជាការលំបាក ក្នុងករណីជនត្រូវចោទស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នបែបនេះ។

៤៧. លើសពីនេះទៀត ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានការប្រិតប្រៀងក្នុងការរៀបចំពាក្យពេចន៍អត្ថន័យ បានបន្ទោសជនត្រូវចោទ និងមេធាវីការពារក្តីចំពោះ ការប្រកាន់យកនូវឥរិយាបទមួយ ដែលមិននាំឲ្យមានកិច្ចដំណើរការនីតិវិធីឲ្យទាន់ពេលសមស្រប។ មេធាវីការពារក្តីសូមអះអាងថា ក.ស.ច.ស នៅក្នុងការកត់សំគាល់នេះ បានព្យាយាមរំលោភសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទ ហើយផ្តល់យុត្តិកម្មមិនត្រឹមត្រូវចំពោះកង្វះខាតនៃការវិវត្តន៍ក្នុងកិច្ចការរបស់ខ្លួន។

---

[30] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី៣៧។

៤៨.ករណីយុត្តិសាស្ត្រតុលាការអឺរ៉ុបបញ្ជាក់ច្បាស់ថា ជនត្រូវចោទ និងមេធាវីការពារក្តីក្នុងកាលៈទេសៈណាក៏ដោយ មិនអាចត្រូវបានបង្ខំ ឬរំពឹងឲ្យធ្វើការសហការជាមួយកិច្ចដំណើរការនីតិវិធីទេ។ អត្ថន័យនៃវិធាននេះគឺជាគោលការណ៍ដែលជនត្រូវចោទម្នាក់ មិនចាំបាច់សហការជាមួយអាជ្ញាធរតុលាការ ដើម្បីឲ្យគេបង្ហាញថាការចោទប្រកាន់ធ្វើឡើងប្រឆាំងនឹងជនត្រូវចោទមានលក្ខណៈត្រឹមត្រូវពិតប្រាកដ។

៤៩. សិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺជាគន្លឹះសំខាន់របស់សិទ្ធិទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវរបស់ជនត្រូវចោទ ដែលត្រូវបានធានាដោយបទដ្ឋានការពារសិទ្ធិមនុស្សជាអន្តរជាតិ[31]។ ចំពោះសំណុំរឿងក្តី *Eckle v. Germany* តុលាការអឺរ៉ុប បានសម្រេចថា ទោះបីជាលោក និងលោកស្រី *Eckle* កាលពីពេលមុនធ្លាប់ប្រឡូកយ៉ាងសកម្ម ក្នុងសកម្មភាពដែលអាចបណ្តាលឲ្យមានការពន្យាពេលក៏ដោយ (មិនដូចក្នុងករណីអៀង ធីរិទ្ធទេ) ក៏ពួកគាត់មិនតម្រូវឲ្យសហការយ៉ាងស្អិតរមួតជាមួយនឹងតុលាការដែរ។ តុលាការអឺរ៉ុបបានថ្លែងថា៖

> "ក្រៅពីមិនបានជួយជម្រុញដំណើរការក្តីឲ្យប្រព្រឹត្តទៅបានរហ័សហើយនោះ លោក និងលោកស្រី Eckle បានធ្វើសកម្មភាពនានា - រួមមានការដាក់បណ្តឹងសើរើជាប្រព័ន្ធចំពោះចៅក្រម - ដែលសុទ្ធតែជាសកម្មភាព មានចេតនាពន្យាពេល។ សកម្មភាពមួយចំនួន នៃសកម្មភាពទាំងនេះ អាចបកស្រាយបានថាជាសកម្មភាព នៃការរារាំងដោយចេតនា (...)។
>
> ប៉ុន្តែ ដូចដែល គណៈកម្មការបានលើកឡើងយ៉ាងត្រឹមត្រូវរួមមកហើយថា មាត្រា៦មិនតម្រូវឲ្យអ្នកដាក់ពាក្យសុំត្រូវសហការយ៉ាងសកម្មជាមួយនឹងតុលាការនោះទេ ហើយក៏

[31] សូមមើលសាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 19187/91 ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ កថាខណ្ឌ ៦៨ ជាឧទាហរណ៍ ចំពោះសំណុំរឿងក្តី *Saunders v. the United Kingdom*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 8130/78 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ ៨២ របស់សំណុំរឿងក្តី *Eckle v.Germany* (ដូចមានភ្ជាប់ជូនជាសំអាងក្នុងការបដិសេធ)។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 13089/87 ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៣ កថាខណ្ឌ ៤៣ របស់សំណុំរឿងក្តី *Dobbertin v. France*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 18954/91 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ កថាខណ្ឌ ៧៩ របស់សំណុំរឿងក្តី *Zana v. Turkey*។

មិនស្តីបន្ទោសពួកគាត់ដែរ ចំពោះការដែលពួកគាត់ព្យាយាមប្រើប្រាស់ដំណោះស្រាយជាជំនួយ ដូចដែលមានចែងក្នុងច្បាប់ជាតិ[32]"។

៥០. ចំនុចមួយក្នុងចំណោមចំនុចផ្សេងៗទៀត ដែលកំណត់ ថាតើ ដំណើរការស៊ើបអង្កេតរបស់ ក.ស.ច.ស ប្រព្រឹត្តទៅក្នុងរយៈពេលមួយសមស្របឬយ៉ាងណា ដោយពិចារណាដោយឡែកទៅលើរយៈពេលដែលជនត្រូវចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួននោះ គឺអាកប្បកិរិយារបស់ភាគី។ ក.ស.ច.ស ហាក់បីដូចជាចង់ឱ្យជនត្រូវចោទ និងមេធាវីការពារក្តីរបស់គាត់ទទួលខុសត្រូវចំពោះការដែលគាត់មិនបានសហការយ៉ាងសកម្ម ហើយដោយ ក.ស.ច.ស មិនបានបញ្ជាក់ ទាល់តែសោះថា តើការសហការនោះរួមមានអ្វីខ្លះ ដែលពួកគេបានប្រើពាក្យពេជន៍ ដែលអាចជាការស្តីបន្ទោសមេធាវីការពារក្តី ចំពោះយុទ្ធសាស្ត្រដែលមេធាវីការពារក្តីបានប្រើកន្លងមកនោះ។

៥១. មេធាវីការពារក្តីគ្មានជាប់កាតព្វកិច្ចត្រូវតែសហការយ៉ាងសកម្មជាមួយនឹងក.ស.ច.ស នោះទេ ហើយមេធាវីការពារក្តីក៏មិនត្រូវទទួលការបន្ទោសចំពោះការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួនដែរ។ ដូច្នេះ ក.ស.ច.ស ប្រើវិធីសាស្ត្រទម្លាក់កំហុសនេះទៅលើជនត្រូវចោទចំពោះ "អាកប្បកិរិយា" មិនព្រមសហការនេះ ដើម្បីជាការឆ្លើយតបទៅនឹងការចោទប្រកាន់របស់មេធាវីការពារក្តី ចំពោះការដែល ក.ស.ច.ស មិនបានបង្ហាញពីការព្យាយាមបំពេញតួនាទី ដោយការយកចិត្តទុកដាក់ នៅក្នុងដំណើរការស៊ើបអង្កេតរបស់ខ្លួន ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ។

៥២. ក្នុងពេលដែលធ្វើការពិនិត្យទៅលើការការប្រព្រឹត្តខ្លួនរបស់អ្នកប្តឹងឧទ្ធរណ៍ ក្នុងដំណើរការផ្លូវច្បាប់ មេធាវីការពារក្តីបញ្ជាក់ថា ជនត្រូវចោទមិនស្ថិតក្រោមកាតព្វកិច្ចដែលតម្រូវឱ្យសហការយ៉ាងសកម្មជាមួយនឹងអាជ្ញាធរនោះទេ[33] ហើយក៏មិនត្រូវមានកាតព្វកិច្ចណាមួយ

---

[32] សូមមើលសាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 8130/78 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ ៨២ របស់សំណុំរឿងក្តី *Eckle v. Germany* (ដូចមានភ្ជាប់ជូនជាសំអាងក្នុងការបដិសេធ)។

[33] សូមមើលសាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 8130/78 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ ៨២ របស់សំណុំរឿងក្តី *Eckle v. Germany* (ដូចមានភ្ជាប់ជូនជាសំអាងក្នុងការបដិសេធ)។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 8304/78 ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ កថាខណ្ឌ ៤២ របស់សំណុំរឿងក្តី *Corigliano v. Italy* ។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 13089/87 ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៣ កថាខណ្ឌ ៤៣ របស់សំណុំ រឿងក្តី *Dobbertin v. France*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 35742/97

ដែលតម្រូវឲ្យប្រព្រឹត្តសកម្មភាពតាមបែបនោះ ដើម្បីបង្រួញដំណើររឿងក្តីដែរ[34]។ ក.ស.ច.ស មិនអាចដាក់ទម្លាក់បន្ទុកនៃដំណើរការយឺតយ៉ាវនៃការស៊ើបអង្កេតរបស់ខ្លួននេះ ទៅលើជនត្រូវចោទទេ ហើយរាល់ការព្យាយាមណាមួយក្នុងការទម្លាក់បន្ទុកនេះ គឺជាការបង្កឲ្យមានការរំលោភបំពានទៅលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទ។

៥៣. ដោយឡែក ជនត្រូវចោទមិនមានកាតព្វកិច្ចណាមួយត្រូវជួយជ្រោមជ្រែងនៅក្នុងការស៊ើបអង្កេតអំពីបទចោទព្រហ្មទណ្ឌចំពោះខ្លួននោះទេ។ ការចោទប្រកាន់ត្រូវតែមានសំណុំរឿងក្តីយកមកបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយវាក៏មិនមែនកាតព្វកិច្ចរបស់មេធាវីការពារក្តីក្នុងការជួយសហការនៅក្នុងរឿងនេះដែរ ទោះជាដោយវិធីសាស្ត្រណាក៏ដោយ។ តុលាការអឺរ៉ុប បានសម្រេចនៅក្នុងរឿងក្តីរបស់ *Nemeth v. Hungary* ថា៖

> "ចាំបាច់ត្រូវតែពិចារណាដល់អង្គហេតុដែលថា អ្នកដាក់បណ្តឹងឧទ្ធរណ៍មិនត្រូវទទួលការបន្ទោសចំពោះការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់នោះទេ ហើយអយ្យការត្រូវទទួលបន្ទុកក្នុងការស្វែងរកសក្ខីកម្ម មកបញ្ជាក់ចំពោះការចោទប្រកាន់មកលើរូបគាត់។ នៅក្នុងស្ថានភាពបែបនេះ អ្នកដាក់ពាក្យសុំមិនតម្រូវឲ្យទទួលការដាក់ទោសចំពោះបញ្ហាអសកម្មដោយមិនបានបញ្ជាក់ពីពេលវេលាជាក់លាក់នោះទេ[35]"។

៥៤. ដូច្នេះ ជនត្រូវចោទ និងមេធាវីការពារក្តីរបស់ខ្លួន មិនត្រូវទទួលរងការចោទប្រកាន់ចំពោះការយឺតយ៉ាវនៃដំណើរការនីតិវិធី ដោយគ្រាន់តែប្រើសិទ្ធិនៅស្ងៀមមិនតបឆ្លើយរបស់ខ្លួននោះទេ។

---

ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៥ របស់សំណុំរឿងក្តី *Ledonne v. Italy*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 36719/97 ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៤ របស់សំណុំរឿងក្តី *Saccomanno v. Italy*។ សាលក្រមអង្គជំនុំ ជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 33969/96 ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ២៣ របស់សំណុំរឿងក្តី *De Blasiis v. Italy*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 35848/97 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ៨១ របស់ សំណុំរឿងក្តី *Barfuss v. Czech Republic*។ សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 16419/90 និង 16426/90 ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៩៥ កថាខណ្ឌ ៦៦ របស់សំណុំរឿងក្តី *Yagci និង Sargin v.Turkey*។ សាលក្រមអង្គជំនុំ ជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 34947/97 ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៧៥ របស់សំណុំរឿងក្តី *Richet v. France*។

[34] សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 8990/80 ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៤ កថាខណ្ឌ ៣៤ របស់សំណុំរឿងក្តី *Guincho v. Portugal*។

[35] សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការអឺរ៉ុប No. 60037/00 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ កថាខណ្ឌ ២៩ របស់សំណុំរឿងក្តី *Nemeth v. Hungary* ។

៥៥. ក.ស.ច.ស គឺជាអាជ្ញាធរដែលមានអំណាច មធ្យោបាយ និងភារកិច្ចក្នុងការស៊ើបអង្កេត បទឧក្រិដ្ឋ ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយ ក.ស.ច.ស មានកាតព្វកិច្ចក្នុងការរៀបចំការស៊ើបអង្កេតរបស់ខ្លួនទៅតាមផ្លូវច្បាប់ ក្នុងបរិបទមួយ ដែលអាចស្វែងរកយុត្តិធម៌បាន ដោយស្ថិតក្នុងរយៈពេលមួយដែលសមហេតុសមផល ជាពិសេស ក្នុងអំឡុងពេលដែលជនត្រូវចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួន រងចាំសវនាការ។ ការទទួលខុសត្រូវនេះ មិនស្ថិតក្នុងកាតព្វកិច្ចរបស់មេធាវីការពារក្តី ដែលត្រូវបញ្ជាក់តាម រយៈការសហការរបស់ខ្លួន ដើម្បីជម្រុញឲ្យដំណើររឿងក្តីប្រព្រឹត្តទៅដោយឆាប់រហ័ស នោះទេ។ ការទទួលខុសត្រូវនេះគឺជាបន្ទុករបស់ ក.ស.ច.ស ទោះបីជាមាន ឬមិនមានវត្ត មានការជ្រោមជ្រែងរបស់មេធាវីការពារក្តីក៏ដោយ។ លុះត្រាតែមេធាវីការពារក្តីបាន ប្រព្រឹត្តសកម្មភាព ក្នុងបំណងបង្កឲ្យមានការយឺតយ៉ាវជាក់ស្តែងដល់ដំណើរការតុលាការ បើមិនដូច្នោះទេ មេធាវីការពារក្តីមិនត្រូវទទួលការ បន្ទោសចំពោះរាល់ការពន្យាពេលនានា នៅក្នុងដំណាក់កាលស៊ើបអង្កេតនៃដំណើរការនីតិវិធីនោះទេ។

៥៦. ជនត្រូវចោទ និងមេធាវីការពារក្តីរបស់ខ្លួន មិនបានប្រព្រឹត្តសកម្មភាពណាមួយ ដែលបង្ក ឲ្យមានភាពយឺតយ៉ាវចំពោះដំណើរការនីតិវិធីនេះទេ។ ការដាក់ចេញនូវដីកាសម្រេចអំពី ការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយទម្លាក់កំហុសចំពោះការយឺតយ៉ាវ ទៅ លើមេធាវីការពារក្តីនោះ គឺជាការរំលោភបំពានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដូច្នេះ ដីកា សម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចចាត់ទុកជា សេចក្តី សម្រេចតុលាការដែលស្របច្បាប់ទៀតទេ ហើយដីកាសម្រេចនេះត្រូវចាត់ទុកជាមោឃៈ។

## ៣.៤ មិនបានបញ្ជាក់ពី "ហានិភ័យជាក់លាក់"

៥៧. ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន បានថែងថា៖ "វាមានហានិ ភ័យមួយជាក់ច្បាស់ គឺថា សាក្សីទាំងនេះនឹងមិនធ្វើការសហការណ៍ឲ្យបានស៊ីជម្រៅ ក្នុងដំណើរការនៃនីតិវិធីទេ ប្រសិនបើ អៀង ធីរិទ្ធ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ[36]"។

[36] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២៦។

ក.ស.ច.ស បានធ្វើការសន្និដ្ឋានចំពោះ "ហានិភ័យជាក់លាក់" ដែលកើតមានតាមរយៈ ហេតុផល ដូចតទៅនេះ៖

- ជនត្រូវចោទស្គាល់ឈ្មោះសាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងរឿងក្តី ដែលគាត់អាច កំណត់អត្តសញ្ញាណរបស់សាក្សីទាំងនោះបាន
- សាក្សីខ្លះៗទៀតក្នុងចំណោមសាក្សីទាំងនេះ អាចនឹងត្រូវបានស្តាប់ចម្លើយឡើងវិញ ហើយពួកគេក៏បានបង្ហាញផងដែរពីឈ្មោះរបស់ជន ដែលអាចនឹងក្លាយជាសាក្សី ផ្សេងៗទៀត ដែលអាចនឹងត្រូវស្តាប់ចម្លើយនាពេលអនាគត
- "វាមានហេតុផលដែលអាចនាំឱ្យជឿជាក់បានថា សាក្សីអាចនឹងទទួលរងការគាប សង្កត់ ព្រោះអាចបណ្តាលមកពីហេតុដែលថា ពួកគេធ្លាប់ជាអ្នកនៅក្រោមបង្គាប់ របស់ជនត្រូវចោទ ឬដោយសារតែមុខតំណែងជាន់ខ្ពស់របស់ជនត្រូវចោទ ប្រសិនបើ និយាយដោយទូលំទូលាយ"
- ហានិភ័យនេះវាពិតជាក់ស្តែង ហើយដែលត្រូវបានបញ្ជាក់គាំទ្រដោយឥរិយាបថ និង សម្តីជាសាធារណៈរបស់ជនត្រូវចោទ ដោយយោង "ឧប្បត្តិហេតុ" ដែលកើតមានក្នុង ឆ្នាំ១៩៩៩ និងឆ្នាំ២០០៣ ជាបន្តបន្ទាប់[37]។

៥៨. ក.ស.ច.ស មិនបានបង្ហាញ "ហានិភ័យជាក់លាក់" ដែលមាននោះ ថា (i) ជនត្រូវចោទ នឹងជះឥទ្ធិពលទៅលើសាក្សីដោយផ្ទាល់ ឬដោយប្រយោល (ii) ហើយការជះឥទ្ធិពលបែប នោះ នឹងជម្រុញឱ្យសាក្សីបដិសេធចូលរួមនៅក្នុងដំណើរការនៃនីតិវិធីនាពេលអនាគត ឬ យ៉ាងណានោះទេ។ លើសពីនេះទៅទៀត របាយការណ៍មួយចំនួនដែលស្តីអំពីការចុះអនុវត្ត ដីកាឱ្យស៊ើបសួរ បានលើកឡើងអំពីឆន្ទៈគួរឱ្យកត់សម្គាល់របស់សាក្សីក្នុងការចូលរួម សហការនៅក្នុងដំណើរការនីតិវិធី[38] ដោយជាទូទៅគ្មានសាក្សីណាម្នាក់បង្ហាញអារម្មណ៍

---

[37] ដីកាសម្រេចអំពីការបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២៦។

[38] សូមមើលកំណត់ហេតុចម្លើយសាក្សី ក្នុងឯកសារ No.D92/2 (ERN 00204702-00204708) និងក្នុងឯកសារ No. D92/6 (ERN 00204730-00204734)។ សូមមើលរបាយការណ៍ការចុះអនុវត្តដីកាឱ្យចុះស៊ើបសួរ D92/10 (ERN 00204763-00204764) ទំព័រទី២ ដែលបានលើកឡើងពីសាក្សីដែលមានភាពស្ទាក់ស្ទើរ ប៉ុន្តែមិនបានបង្ហាញពីសញ្ញាណបទឧក្រិដ្ឋ ពាក់ព័ន្ធនឹងជនត្រូវចោទ ហើយក៏មិនមានសាក្សីណាម្នាក់បានលើកឡើងពីការព្រួយបារម្ភទាក់ទងនឹងជនត្រូវចោទជាទូទៅ ឬក៏ ការព្រួយបារម្ភចំពោះការដោះលែងជនត្រូវចោទពីការឃុំខ្លួនបណ្តោះអាសន្នជាពិសេសនោះដែរ។

យកចិត្តទុកដាក់ចំពោះឥទ្ធិពលរបស់ជនត្រូវចោទ ឬទៅលើការដោះលែងជនត្រូវចោទពីការឃុំខ្លួនបណ្ដោះអាសន្ននោះទេ។

៥៩. ពាក្យពេចន៍ដ៏ម៉ឺងម៉ាត់ ដែលបានប្រើនៅក្នុងដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន បានលើកឡើងពីវត្តមានរបស់ភស្តុតាងជាមូលដ្ឋានដែលមាន ប៉ុន្តែតាមពិតភស្តុតាងទាំងនោះមិនមាននោះទេ។ ក.ស.ច.ស មិនទាន់បានបន្ថែមភស្តុតាងនានាចូលទៅក្នុងសំណុំរឿងក្ដីនៅឡើយទេ ចាប់តាំងពីពេលដែលមានការចាប់ខ្លួនជនត្រូវចោទ ដែលនេះបញ្ជាក់ចំពោះការដែលចោទប្រកាន់ថា មានហានិភ័យដោយជនត្រូវចោទអាចប្រើឥទ្ធិពលរបស់ខ្លួនទៅលើសាក្សីនានា ប្រសិនបើគាត់ត្រូវបានគេដោះលែង ឬប្រសិនបើសាក្សីបដិសេធមិនបន្តសហការជាមួយអ.វ.ត.ក។

៦០. អ្វីទៅដែលអាចចាត់ទុកថាជាភស្តុតាងជាបទដ្ឋានគ្រប់គ្រាន់ សម្រាប់ការចាប់ផ្ដើមដំណើរការនីតិវិធីតុលាការមួយបាននោះ - ប្រសិនបើយោងទៅលើហេតុការណ៍ដែលបានកើតឡើងក្នុងឆ្នាំ១៩៩៩ និង២០០៣[39] - វាលែងមានសុពលភាពគ្រប់គ្រាន់ហើយបន្ទាប់ពីការឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលមួយឆ្នាំហើយនោះ។ ក.ស.ច.ស មានឱកាសស្វែងរកមូលដ្ឋាន សមស្របមួយសម្រាប់បញ្ជាក់ពី "ហានិភ័យជាក់លាក់" នានាដែលធ្វើឱ្យសាក្សីមានការព្រួយ បារម្ភពាក់ព័ន្ធនឹងការដែលការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទឈានមកដល់ទីបញ្ចប់ ប៉ុន្តែ *គ្មាន* សាក្សីណាម្នាក់សោះដែលបានបង្ហាញពីភាពភ័យខ្លាចនេះទេ។ ក.ស.ច.ស ក៏មិនបានផ្ដល់មូលដ្ឋានសម្រាប់ការអះអាងអំពីការចោទប្រកាន់ថាមាន "ហានិភ័យជាក់លាក់" នោះដែរ។

៦១. ដោយយោងទៅលើអង្គហេតុគ្មានសាក្សីណាម្នាក់សោះ បានផ្ដល់ភស្តុតាងអំពីការចោទប្រកាន់ដែលមានទៅលើជនត្រូវចោទ នោះគ្មានមូលដ្ឋានអ្វីដែល ក.ស.ច.ស អាចធ្វើការសន្និដ្ឋានបានថា មានការភ័យខ្លាចចំពោះការបញ្ចប់នូវរយៈពេលឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទនោះទេ។

---

39 សូមមើលលេខយោង19 ស្ដីអំពី ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ទាក់ទងនឹងឧប្បត្តិហេតុដែលបានកើតឡើងក្នុងឆ្នាំ១៩៩៩ និងឆ្នាំ២០០៣ ដោយផ្អែកទៅលើដីកាឃុំខ្លួនបណ្ដោះអាសន្នលើកដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយ អង្គបុរេជំនុំជម្រះយល់ឃើញថាអាចទទួលយកបាន។

៦២. ជាទូទៅ សម្រាប់យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបបានសម្រេចថា ហានិភ័យកើតឡើងពីការគាបសង្កត់ទៅលើសាក្សី នឹងត្រូវលុបបំបាត់នៅពេលដែលដំណើរការក្តីមានការវិវឌ្ឍ[40]។ នៅក្នុងរឿងក្តី *Clooth v. Belgium* តុលាការនេះបានសម្រេចថា៖

"តុលាការទទួលស្គាល់ថា វាជាសំណុំរឿងក្តីមួយដែលស្មុគស្មាញជាទីបំផុត ដែលធ្វើឱ្យការសួរគឺជាការងារដ៏លំបាក។ តាមការប្រព្រឹត្តខ្លួនរបស់គាត់ (...) លោក Clooth បានរារាំង និងបានពន្យាពេលដំណើរការនីតិវិធីក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ ការជឿជាក់របស់តុលាការថា ត្រូវតែរក្សាគាត់ទុកនៅក្នុងមន្ទីរឃុំឃាំង ដើម្បីជៀសវាងកុំឱ្យគាត់ទៅរំខានដល់ការស៊ើបសួរគឺជា រឿងគួរឱ្យងាយយល់ណាស់ ជាពិសេសនៅដំណាក់កាលដំបូងៗនៃការសាកសួរ។

សម្រាប់រយៈពេលយូរអង្វែង លក្ខខណ្ឌនៃការស៊ើបអង្កេតមិនមែនជាលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ធ្វើសនិទានកម្មក្នុងការឃុំខ្លួនរបស់ជនសង្ស័យៈទេ។ ក្នុងហេតុការណ៍ទូទៅហានិភ័យដែលចោទប្រកាន់នឹងត្រូវកាត់បន្ថយ ទៅតាមពេលវេលា ដោយសារការស៊ើបសួរមានប្រសិទ្ធភាព ការស្តាប់យកចម្លើយសាក្សីត្រូវបានធ្វើ និងការផ្ទៀងផ្ទាត់ត្រូវបានធ្វើ[41]"។

៦៣. ដោយពិចារណាទៅលើហានិភ័យនេះ តុលាការអឺរ៉ុបបានថ្កោលទោសសមត្ថកិច្ចតុលាការដោយបញ្ជាក់ថា៖

"សមត្ថកិច្ចតុលាការមិនបានចង្អុលបង្ហាញនូវហេតុផលណាមួយ ដែលបង្ហាញថា ហានិភ័យដែលសមត្ថកិច្ចគិតថាមាននោះ ពិតជាមានជាក់ស្តែងមែន និងខកខានមិនបានបញ្ជាក់ថា អ្នកដាក់ពាក្យសុំ - ជាជនដែលគ្មានសាវតារ និងមានតួនាទីតូចតាក្នុងក្រុមម៉ាហ្វីយ៉ា (...) អាចបង្កគ្រោះថ្នាក់នោះទេ។ ការដែលមិនមានភស្តុតាងបញ្ជាក់នឹងធ្វើឱ្យការចោទប្រកាន់មកលើអ្នកដាក់បណ្តឹងឧទ្ធរណ៍កាន់តែចុះខ្សោយទៅៗ មិនមែនខ្លាំងទៅនោះទេ នៅពេលដែលពេលវេលាចេះតែកន្លងផុតទៅ[42]"។

---

[40] សូមមើលរឿងក្តី សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍តុលាការអឺរ៉ុប Nos. 12325/86 និង 14992/89 ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩១ របស់សំណុំរឿងក្តី *Kemmache v. France* កថាខណ្ឌ ៥៣។

[41] សូមមើលរឿងក្តី សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍តុលាការអឺរ៉ុប No. 12718/87 ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩១ របស់សំណុំរឿងក្តី *Clooth v. Belgium* កថាខណ្ឌ ៤៣។

[42] សូមមើលរឿងក្តី សាលក្រមអង្គជំនុំជម្រះឧទ្ធរណ៍តុលាការអឺរ៉ុប No. 26772/95 ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ របស់សំណុំរឿងក្តី *Labita v. Italy* កថាខណ្ឌ ២៦។

៦៤. មូលហេតុដូចមានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមធ្វើការសន្និដ្ឋានថា ក.ស.ច.ស ខកខានក្នុងការផ្តល់នូវហេតុផលសម្រាប់គាំទ្រចំពោះការសន្និដ្ឋានរបស់ខ្លួន ដែលបានលើកឡើងថា មានហានិភ័យ "ជាក់លាក់" ដែលអាចធ្វើឱ្យសាក្សីបដិសេធមិនព្រមចូលរួមក្នុងដំណើរការនីតិវិធីនានា[43] ប្រសិនបើការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទមិនត្រូវបានពន្យាទេនោះ។ ដូច្នេះ ដូចបានលើកឡើងរួចមកហើយ ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានកំហុស ដែលតម្រូវឱ្យមានការប្តឹងឧទ្ធរណ៍នៅពេលនេះ។ ហេតុដូច្នេះហើយ ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវចាត់ទុកជាមោឃៈ។

## IV. **សេចក្តីសន្និដ្ឋាន**

៦៥. យោងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ខកខានមិនបានបំពេញទៅតាមបទដ្ឋានជាច្រើនដែលមានចែងក្នុងវិធាន៦៣(៣) និង ៦៣(៧) នៃវិធានផ្ទៃក្នុង។ ទីមួយ សេចក្តីសម្រេចមិនមានហេតុផលគ្រប់គ្រាន់។ ទីពីរ ដីកាមានព័ត៌មានមិនពិតជាច្រើន។ ទីបី ដីកាអនុវត្តទៅតាមបទដ្ឋានមិនត្រឹមត្រូវ ខុសពីបទដ្ឋានគតិយុត្តនានា។ ទីបួន ដីកានេះរំលោភសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទ។ ទីបញ្ចប់នោះ គឺការអះអាងរបស់ដីកាដែលលើកឡើងថាមាន ហានិភ័យ "ជាក់លាក់" ដែលជនត្រូវចោទអាចជះឥទ្ធិពលទៅលើសាក្សីនានានោះ មិនមានភស្តុតាង ជាមូលដ្ឋានច្បាស់លាស់នោះទេ។

៦៦. ជាសរុប មេធាវីការពារក្តីសុំដាក់ជូនសេចក្តីសន្និដ្ឋានថា ការស៊ើបអង្កេតរបស់ ក.ស.ច.ស ដែលបានប្រព្រឹត្តទៅនាពេលថ្មីៗនេះ មិនបានធ្វើឡើងឱ្យទាន់ពេលវេលានោះទេ ដែលបង្កឱ្យមានជាផលប៉ះពាល់អវិជ្ជមានដល់ការខិតខំប្រឹងប្រែង ក្នុងការស៊ើបអង្កេតរបស់ ក.ស.ច.ស។ ហេតុផលនេះជាការរំលោភបំពានសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវទទួលការវិនិច្ឆ័យនៅក្នុងរយៈពេលមួយសមរម្យ ជាពិសេសដោយពិចារណាទៅលើអង្គហេតុដែលជនត្រូវចោទបាន ស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលលើសពីមួយ

[43] ដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ២៦

ឆ្នាំកន្លងមកហើយ ខណៈដែល ក.ស.ច.ស មិនមានលទ្ធភាពក្នុងការបង្ហាញថាខ្លួនបាន អនុវត្តនូវសមត្ថកិច្ចដ៏ត្រឹមត្រូវរបស់ខ្លួន ក្នុងដំណើរការស៊ើបអង្កេតចំពោះរឿងក្ដីរបស់ ជនត្រូវចោទ។ ដូច្នេះ ក.ស.ច.ស ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការពន្យាពេលនេះ។

៦៧. ព័ត៌មាន "ដ៏តិចតួច" ដែល ក.ស.ច.ស បានព្យាយាមដាក់ចូលទៅក្នុងសំណុំរឿងក្ដី សម្រាប់រយៈពេលលើសពីមួយឆ្នាំ អំពីតួនាទីដែលជនត្រូវចោទអាចកាន់កាប់នៅក្នុងរបប នោះ គឺមិនមាន លក្ខណៈគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការពន្យាពេលការឃុំខ្លួនបណ្ដោះ អាសន្ននេះទេ។ ក.ស.ច.ស មិនបានប្រមូលភស្តុតាងពាក់ព័ន្ធនឹងសំណុំរឿងក្ដី ដែលអាច គាំទ្របន្ថែមនឹងផ្ដល់ជាហេតុផលជាក់លាក់ដើម្បីអាចឲ្យជឿជាក់បានថា ជនត្រូវចោទបាន ប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់មែននោះទេ។ ការឃុំខ្លួនបណ្ដោះអាសន្នកាន់តែ មានរយៈបន្លាយ ផលលំបាកនឹងកាន់តែធ្ងន់ធ្ងរ។ ក.ស.ច.ស ក៏មិនបង្ហាញផងដែរនូវ ភស្តុតាងបទឧក្រិដ្ឋ ទៅលើជនត្រូវចោទ សម្រាប់រយៈពេលមួយឆ្នាំដែលគាត់ស្ថិតនៅក្នុង ការឃុំខ្លួន។ ដូច្នេះ លក្ខខណ្ឌតម្រូវមិនត្រូវបានគោរព ហើយការឃុំខ្លួនបណ្ដោះអាសន្នក៏ មិនអាចនឹងពន្យាបានតទៅទៀតដែរ។

៦៨. ការរំលោភបំពានទាំងនេះ មានលក្ខណៈកាន់តែធ្ងន់ធ្ងរទៅទៀតដោយសារតែអង្គហេតុ ដែលមិនទាន់មានភាពច្បាស់លាស់ ថាតើនៅពេលណាដែលរឿងក្ដីនឹងត្រូវបានជំនុំជម្រះ។

## V. សំណើ

៦៩. តាមរយៈហេតុផលដូចបានរៀបរាប់ខាងលើ មេធាវីការពារក្ដីស្នើសុំអង្គបុរេជំនុំជម្រះ ដោយគោរព ហើយសូមឱ្យអង្គបុរេជំនុំជម្រះមេត្តា៖

(១) សម្រេចថា លក្ខខណ្ឌដ៏តឹងរ៉ឹងតម្រូវឲ្យមានការបន្តថិរៈវេលាឃុំខ្លួនជនត្រូវចោទ លែងជាលក្ខខណ្ឌសមស្របសម្រាប់ការឃុំឃាំងទៀតហើយ

(២) ចាត់ទុកជាមោឃៈ ចំពោះដីកាសម្រេចអំពីការបន្តថិរៈវេលានៃការឃុំខ្លួនជនត្រូវ ចោទ បណ្ដោះអាសន្នក្នុងរយៈពេលមួយឆ្នាំបន្តទៀត

(៣) សម្រេចដោះលែងជនត្រូវចោទជាបន្ទាន់ ក្រោមលក្ខខណ្ឌដូចដែលបានស្នើឡើងនៅក្នុងការជំទាស់តវ៉ារបស់ខ្លួន ដែលស្នើឡើងដោយមេធាវីការពារក្តី ឬតាមការដែលអង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨

លោក **ផាត់ ពៅសៀង**

Ms. Diana ELLIS, QC

សហមេធាវីការពារក្តី របស់អ្នកស្រី **អៀង ធីរិទ្ធ**